Commonwealth of Massachusetts
Executive Office of Health and Human Services
Executive Office of Elder Affairs

# សិទ្ធិរបស់អ្នកដើម្បីសុំតវ៉ា លទ្ធភាពទទួលចំណុចការបំរើជរាវ័យ

បើអ្នកមិនពេញចិត្តជាមួយការសំរេចអំពី លទ្ធភាពទទួលចំណុចការបំរើជរាវ័យ (Aging Services Access Point - ASAP) ទេ អ្នកអាចជំទាស់ដល់ ការសំរេចនោះបាន ដោយស្នើសូមឲ្យមានការពិនិត្យមើលឡើងវិញ ។

**សិទ្ធិរបស់អ្នក**

- អ្នកមានសិទ្ធិឲ្យបានគេស្តាប់រឿងហេតុ នៅឯអង្គប្រជុំពិនិត្យមើលឡើងវិញ ។
- អ្នកមានសិទ្ធិដើម្បីត្រួតពិនិត្យ និងថតចំឡង (ចំណាយប្រាក់កាសខ្លួនឯង) នូវសេចក្តីទាំងឡាយនៃសំណុំរឿងរបស់អ្នក នៅពេលណាក៏បាន ។
- អ្នកមានសិទ្ធិដើម្បីជ្រើសរើសមនុស្សម្នាក់ ឲ្យធ្វើជាតំណាងអ្នកនៅឯអង្គប្រជុំពិនិត្យមើលឡើងវិញ ។
- អ្នកមានសិទ្ធិដើម្បីស្នើថា ការពិនិត្យមើលឡើងវិញគប្បីធ្វើតាមទូរស័ព្ទ ។

**វិធីពិនិត្យមើលឡើងវិញ**

ការពិនិត្យមើលឡើងវិញ គឺជាការប្រជុំក្រៅផ្លូវការមួយ ដើម្បីដោះស្រាយទំនាស់រវាងអ្នក និងភ្នាក់ងារ ASAP ។ អង្គប្រជុំនេះត្រូវបានធ្វើឡើងដោយគណៈកម្មាធិការផ្ទៃក្នុងនៃ ASAP ។ ការពិនិត្យមើលឡើងវិញអាចធ្វើនៅក្នុងផ្ទះរបស់អ្នក ឬធ្វើនៅឯ ASAP របស់អ្នក ឬក៏អាចធ្វើតាមទូរស័ព្ទបាន ។ បើសិនជា ធ្វើដោយផ្ទាល់មុខអ្នកត្រូវតែអញ្ជើញមកចូលរួមក្នុងអង្គប្រជុំពិនិត្យមើលឡើងវិញឬបញ្ជូនមនុស្សម្នាក់ឲ្យធ្វើជាអ្នកតំណាងអ្នក។ បើសិនជាធ្វើតាមទូរស័ព្ទ អ្នកនឹងពិភាក្សាពីស្ថានការណ៍របស់អ្នក ក្នុងកំឡុងពេលនិយាយគ្នាតាមទូរស័ព្ទ ជាមួយនឹងអ្នកតំណាងពីគណៈកម្មាធិការផ្ទៃក្នុង (Internal Review Commitee)។

អ្នក ឬអ្នកតំណាងរបស់អ្នក នឹងមានឱកាសរៀបរាប់មូលហេតុដែលអ្នកមិនយល់ស្របជាមួយការសំរេច នៅអង្គប្រជុំពិនិត្យមើលឡើងវិញ ឬនៅក្នុងកំឡុង ពេលនិយាយគ្នាតាមទូរស័ព្ទ និងដើម្បីផ្តល់ភស្តុតាង និង/ឬ សាក្សី ឲ្យនិយាយជំនួយអ្នក ។ អ្នក ឬអ្នកតំណាងរបស់អ្នក អាចសួរសំណួរស្តីពីព័ត៌មានដែល បានបង្ហាញដោយ ASAP ។ អ្នកក៏អាចសួរសំណួរទៅអ្នកនិយាយជំនួយ ASAP ស្តីពីការតវ៉ារបស់អ្នក ឬភស្តុតាងដែលបានបង្ហាញដោយកាន់ជើងការ សំរេចរបស់ ASAP ។

បើអ្នកមិនពេញចិត្តជាមួយលទ្ធផលនៃការពិនិត្យមើលឡើងវិញនៃ ASAP ទេ អ្នកមានសិទ្ធិសុំតវ៉ាការសំរេចនោះទៅ (ការិយាល័យប្រតិបត្តិការកិច្ចការ ចាស់ទុំ) Executive Office of Elder Affairs ។

ដើម្បីចាប់ផ្តើមវិធីពិនិត្យមើលឡើងវិញបាន សូមបំពេញក្រដាសបំពេញដែលមានភ្ជាប់មកជាមួយ រួចផ្ញើវាទៅ ASAP ក្នុងរយៈពេលសាមសិប (30) ថ្ងៃ នៃប្រក្រតិទិន ចាប់តាំងពីថ្ងៃអ្នកបានទទួលសេចក្តីជូនដំណឹងពីការសំរេច (Notice of Action) មក ។ បើអ្នកមិនផ្ញើសំណើសំរាប់ការពិនិត្យមើលឡើង វិញ ក្នុងរយៈពេលសាមសិប (30) ថ្ងៃ នៃប្រក្រតិទិនទេ អ្នកនឹងបាត់បង់សិទ្ធិរបស់អ្នកដើម្បីសុំតវ៉ាហើយ ។

សេចក្តីភ្ជាប់ : សំណើសំរាប់ការពិនិត្យមើលឡើងវិញ